ដើរទៀនទិញទៅ ។

ខុនណាផងចាស់ៗ ឆ្អិតឆ្អើនឆ្អៃណាស់ ឆ្អួតចឹកលាបម្សៅ

បែរបើកកញ្ចក់ ឆ្លុះមុខមើលទៅ អង្គឯងផងហាក់នៅ

ក្រមុំពាលពិត ។

ថ្ពាល់ផតសងខាង ចិតចំស្អិតស្អាង បួងសក់កំបិត

សក់សោតសព្រោង ខ្ចងកោងដោះស្និត ក្អែកសោតផងផឹត

ស្រស់រៀបថង់ស្វា ។

ឆ្មាញបាក់គ្រហុប បបូរមាត់ខុប គួរគិតអនិច្ចា

នៅគង់តែពង ចំស្អាងអាត្មា ឡើងលើរថា

ជាន់ជិះបរទៅ ។

ខ្លះជិះគ្រែស្នែង ពលពាលសោតសែនដង្ហែខ្លល់ខ្មៅ

ខ្លះអង្រឹងយួន ស្នែងបួនដើរទៅ ខ្លះដើរសំដៅ

អង្គុយភោគថែម(១) ។

– ស្រីផងស៊ីស្វា ជួបជុំគ្នា(២) ញញឹមញញែម

ដើរកន្ទោងគ្រប់ រៀបរបស៊ីនសឹម នាងខ្លះធ្វើណែម

---

១– ច្បាប់ខ្លះថា ឡើងលើកេងថែម ។ ពាក្យ «កេងថែម» នេះ ពុំនឹងជាមានន័យ ដូចម្ដេច? ។ ២ ច្បាប់ខ្លះថា ស្រាយថង់ស៊ីស្វា ជួបជុំចរចា ... ។



ធ្វើនំបាក់ង ។

នំផ្ទៃទំគម នំកូរអន្សម កន្ទ្រាមបាបចាំង

នំបុ័កចុន ច្រើនជាន់មានទាំង នំក្រៀមក្រៀបអាំង

ក្រាបល្ងួកងខ្សៀន ។

ខ្លះធ្វើនំបៅ ខ្លះធ្វើអម្សៅ សណ្ដែកនំទៀន

នំចន់ពេញខ្ទប់ នូវនំផ្ទៃមៀន នំដូងក្រវៀន

នំខ្ញីសង់ខ្យា ។

ខ្លះធ្វើនំក្រៀប បត់បានដាក់ត្រៀប នំកន្ទុយប្រា

លំអងរំបេក ពងលេខផ្កាលា នូវនំបាយស្រា

នំគ្រក់ក្រូចក្រាយ ។

នំខ្ទុតក្របៅ នំបង់ខ្ញាញ់នៅ នំឈ្មោះប្រពាយ

ត្រាបលាជនំត្រាប នូវនំផលអាយ នំស្រួយនំផ្កាយ

គ្រប់ពណ៌ស្រេចស្រាប់ ។

ខ្លះលូកដៃឈោង ទៅយកកន្ទោង រករៀបដណាប់

ត្រឡាចល្ហុងត្នោត កន្ទួតគ្រប់គ្រាប់ ម្នាស់ស្វាយទទាប់

ចេកខ្នុរពុទ្រា ។

ខ្លះធ្វើសម្ល    ហុងហើយខ្លួន    ទឹមមាន់ទឹមទា
ខ្លះស្លាជើងជ្រូក    គ្រាប់ល្ហុកលាយគ្នា    ខ្លះញាំខ្លះក្លា
ខ្លះក្អកលមើល ។

ខ្លះស្លាសារសៃ    ខ្លះស្លាមើមស្ពៃ    ខ្លះក្អកបណ្ដើរ
ខ្លះស្លម្ជូរថ្មឹង    ផ្សំនឹងសាច់ផ្អើរ    ខ្លះអាំងទុកធ្វើ
ស្លផ្កាត្រថុក ។

ខ្លះបេះសាច់ទា    សាច់មាន់ស្លជា    ទឹកនំបញ្ចុក
ខ្លះស្លប្រហើរ    ខ្លះធ្វើហាហុក    ធ្វើខ្យងសម្រុក(១)
បណ្ដាញក្រៀវផង ។

ខ្លះស្លទំពាំង    ខ្លះបេះត្រីអាំង    ញាំនឹងសម្រង
ខ្លះញាំពោះប្រា    ខ្លះក្លាបន្ទង    ខ្លះយកអង្ក្រង
ញាំនឹងប្រស់ស្លា ។

· កាលនោះមន្ត្រី    សេនាបតី    ឡើងទូលក្សត្រា
បពិត្រយើងខ្ញុំ    រៀបចំគ្រប់គ្នា    ប្រដាប់ប្រដា
គ្រប់គ្រាន់ស្រេចស្រាប់ ។

---

១– ខ្យងសម្រុក ជាឈ្មោះម្ហូបមួយមុខ របស់ខ្មែរពីដើម ជាម្ហូបដែលត្រូវលើកជូនភ្ញៀវក្រោយបង្អស់ ក្នុងឱកាសមានពិធីអាពាហ៍ពិពាហ៍ ។



ក្សត្រថ្វៃឥស្សូរ    ស្ដាប់មន្ត្រីទូល    ទើបស្ដេចប្រញាប់
រើសរកកូនស្រី    មន្ត្រីគួរគាប់    ឲ្យមានសណ្ដាប់
សន្ដានពង្ស ។

ខ្លះរៀបដើរហែ    កាន់ផ្ចិតបក់បៃ    ញញឹមចះបា
ខ្លះកាន់គ្រប់គ្រឿង    រុងរឿងថ្វៃថ្លា    ស្អិតស្អាងអាត្មា
ហែរាជបុត្រី ។

នាងខ្លះមុខមូល    ថ្ពាល់ម៉ដ្ឋប៉ប៉ូរ    កាន់ព្រះវិជនី
ពីពាក់ពាក់អាវ    លាវខៀវស្រស់ថ្មី    ស្លៀកខៀវផុសក៏
វល្លិ៍សរចនា ។

នាងមួយមុខម៉ដ្ឋ    ខ្លួនស្រគត់    ស្រគំកាយា
ពាក់ពាត់អាវលាវ    ពាក់អាវសោភា    កាន់ព្រះកន្និដ្ឋា
អង្គុយគង់គាល់ ។

នាងមួយមុខស្រស់    កាន់ព្រះសិទ្ធសេ    ពាក់អាវលាវពណ៌-
លឿងដូចមៀត    សក់សៀតផ្កាញ័រ    រៃបញ្ចពណ៌
បួនបត់កេសី ។

នាងមួយមុខប៉ែន    ដោះក្រាលក្បូណែន    កាន់ពានព្រះស្រី
ពាក់អាវលាវខៀវ    ពងរៀវឥន្ទ្រិយ    ស្លៀកខៀវលេចថ្មី

ផុលផុសសឹងផ្កា ។

នាងមួយមុខឈ្នង ផ្កាល់ផូរបំព្រង ផង់ផាត់សុគន្ធា
ពាក់អាវប្លុបប្លាស់ ជំពាស់ហត្ថា កាន់ព្រះកូសា
មាសម័យពណ្ណកយ ។

នាងមួយមុខឈរ ផ្អៀងផ្អងថ្ងូបថ្ងូរ អំពើកែក្រោយ
ផ្កាល់ផូរផាត់ម្សៅ ពាក់អាវលាវស្វាយ ករកាន់ព្រះឆាយ
ព្រះសំអាងអង្គ ។

នាងមួយមុខពហ៊ុ បួងបត់កេសា ផ្កាល់ផាត់ផូរផង់
ពាក់អាវផកគាំ ស្រគាំបញ្ចង់ បញ្ចើមានទ្រង់
កាន់ពានព្រះស្រី ។

នាងមួយមុខដាច់ ដោះតូចទើបចិច ស្លៀកខៀវទេសថ្មី
ពាក់អាវក្រហម ហ្មោកល្មមឥន្ទ្រិយ ស្រគត់ប្រិមប្រិយ
កាន់ពានព្រះពស្ត្រ ។

សឹងពាក់ត្រសាល់ ស្នៀតសក់ផ្កាញើរ សឹងដាំត្បូងបុស្ស
ពាក់ចិញ្ចៀនព្រាល រន្ទាលស្រៀវស្រស់ ស័ក្តិសមកំពស់
កំពុងពេញពាល ។

ស្ដេចឲ្យរើសប្រុស ដោមឆាយស្រៀវស្រស់ ហៃបុត្រកូបាល



សឹងកូនមន្ត្រី ពីសីពិសាល មានរូបត្រកាល
ត្រកូលថ្លៃថ្លា ។

ពាក់កងចិញ្ចៀន ស្លៀកសំពត់ខៀន អាវផាយកាសាវ៍-
ពណ៌ពាក់ករកាន់ សុវណ្ណបទុមា ហៃបុត្រប្រសា
ប្រសើរសោភ័ណ ។

កាន់ព្រះវិជនី កាន់ពានព្រះស្រី ព្រះខាត់ព្រះខាន់
ព្រះសិទ្ធរស ព្រះពស្ត្រកៅទណ្ឌ កាន់ព្រះសោភ័ណ
ព្រះស្រីព្រះឆាយ ។

កាន់ព្រះកន្ទប្ដា ព្រះសុគន្ធា រៀបពល់រៀងពយ
ទន្ទេងទន្ទាំ លំនាំដើតឆាយ កើលកាងកែកាយ
យាសយល់ស័ក្តិសម ។

ទើបស្ដេចឲ្យក្រាល រូបរៀបកម្រាល ព្រះពជពេងរម្យ
ពូកពាសខ្ទាត់ខ្វង ចាត់វែងចៀមចំ ខ្នល់ខ្នើយព្រៃព្រំ
ប៉ាក់ផ្កាករចនា ។

ពិដានពិដាស រំយោលពេញពាស សំយុងមាលា
ស្វេតច្ឆ័ត្រឆាយ រំកាយសោភា បាំងព្រះសន្ធយា
ដុំកុងព្រះបាន ។

ឯអស់មន្ត្រី សេនាបតី ប្រដាប់ខ្លួនប្រាណ
ស្លៀកល្បើកបានខ្មៅ ពាក់អាវផាយប៉ាន ខ្សែស្រាយមាសមាន
តាមបណ្ដាស័ក្ដិ ។

អ្នកខ្លះស្លៀកខៀវ ជរបូរជើងខៀវ ខ្លះស្លៀកសឹងប៉ាក់
បន្ទុកបន្ទាយ ដរផាយល្បើកផ្ទាក់ សឹងខ្សែស្រាយផាក់
រំលេចផុសផ្កា ។

យួរថង់ដៃម្ដាយ ដៃម្ខាងបង់ប្រាយ កាន់ផ្ចិតលីលា
ឡើងលើកដរថ ព្រើនក្ដាត់គ្រៀបគ្រា គង់គាល់រាជា
តាមដោយសក្តិសម ។

ឯអស់ខុនណាង ជំទាវនូវនាង ស្រីផ្កាព្រះស្នំ
លាបប្រេងចន្ទន៍បួន បត់បួនសក់សំ– ពោងពាក់រងំ
រំបពេកា ។

ស្អិតស្អាងត្បូតែង ដណ្ដប់ស្បៃវែង សសឹងកាសារ
យួរថង់ឡើងគាល់ រៀងរាល់រៀបគ្នា តាមដោយសក្ដា
ធំតូចទីទៃ ។

ទើបព្រះមហាក្សត្រ ឲ្យស្អាងបុត្រត្ន ពីពេទ្យប្រពៃ



សឹងគ្រឿងទិព្វខេង ចរិញ្ចូនផ្កាថ្ងៃ មែនមានតម្លៃ
ឥតឯតណានា ។

ព្រះពោធិសត្វ ទ្រង់ព្រះមកុដវត្ត រុងរឿងរចនា
អាកមត្ថកាយ ឆើតឆាយសោភា កុណ្ឌលទិព្វ
សង្វារកនក ។

ទ្រង់ព្រះភូសា ផាយប៉ានប៉ាក់ផ្កា ជារូបនាគនរ
ស្រការំលេច សឹងពេជ្រចរ. ហាក់ហែលដើយ-ង
រូបស័ក្ដិសិទ្ធិ ។

ទ្រង់ព្រះព័ស្ត្រផាយ ពណ៌សេតឆើតឆាយ ប៉ាក់ប៉ានល្អពិត
សឹងខ្សែស្រាយសើម ចន្ទមកុះកិត ផាក់ផាំវិចិត្រ
រំលេចក្ខក់ផ្កា ។

ព្រះហស្តទ្រើសទ្រង់ សឹងព្រះខម្រង់ ពេជ្រពិទូរ្យតា-
ទឹមចាំងទឹកវិល មហានិលតាក មរកតមុក្ដា
បទុមកគកាយ ។

ខ្ចប់ព្រះអង្គ មាសម័យសឹងតែ ពេនព័ទ្ធល្អលាយ
ទែនទឹមចាស់ចាក់ ផាំផាក់ត្ថកាយ រឿងរង្សីសាយ

ភ្ញីផ្ទុកពេកក្កាត់ ។

ស្អាប់ព្រះជង្ឃា សុពណ្ណិបាទា សឹងមាសពិចិត្រ
ធ្លាក់ផ្ទៅក្បូរក្បាច់ រំលេចដាំផិត កែវកែមគាល់គិត

រៀបរៀងប្រពៃ ។

ឯនាងសុខុមា- លន្ធាធិកា ទ្រង់គ្រឿងទិព្វថ្លៃ
មកុដកែវកងក អម្ពល្អក្រៃ ហាក់ស្រីសួគ៌ត្រៃ-

ត្រឹង្សាសមសក្តិ ។

នាងទ្រង់ព្រះពស្ត្រ ប្រពៃស្រៀបស្រស់ ខ្សែស្រយដាំដាក់
កាយត្រូវបនា ដោយផ្កាទងទាក់ ទ្រង់ព្រះសុភ័គ

វែងកសល្អល្អះ ។

ខសគុលីទ្រង់(១) សឹងព្រះទម្រង់ រត្នរៀងត្រចះ
ត្រចាចត្រចង់ អស់អង្គហាក់ព្រះ- ចន្ទថែងរៀងរះ

ពីបូព៌ទិសទី ។

លុះបានពេលា នាទីលក្ខណា ឧត្តមយាមបី
ឫក្សប្រើកបីហាន ជោគមានសួស្តី ទើបព្រះពោធិ

ទូវិកជធីតា ។

១ ក្លាយមកពី ខសង្គុលី «ម្រាមដៃ១០» ។



បរបេញផ្ទឹមផ្ទាល់ ឥទអង្គគង់គាល់ ទន្ទឹមជង្ឃា
ប្រញ្ញប្រាណប្រណម្យ បង្គំវន្ទា ព្រះវរបិតា

មាតាក្សត្រី ។

ពីរព្រះមហាក្សត្រ បង្វែរពស្ត្រវជ្ជ ពជប្រពៃពណ៌
ឲ្យពជបុត្រស្នង គ្រប់គ្រងបុរី ចំរើនវង្សី

ទាំងពីរបុត្រភ្ជា ។

អស់អង្គព្រាហ្មណ៍ព្រឹទ្ធ សូត្រសៃ្របសាស្ត្រសិទ្ធ ចំរើនជយា
ផ្កាត់ផ្កាយព្រះពរ បវរសេដ្ឋា សិរីទីឃា-

យុយឺនសួស្តី ។

ផ្គុំត្រៃស័ទ្ធសម ស័ព្ទសូរងំ ទទូងភេរី
គោះគងប្រគំ សូរសមតន្ត្រី សាដៀវខ្លុយប៉ី

ស្រឡៃពាទ្យគង ។

ភ្លេងកងព្រោតទ្រ ចាប៉ីរអ ខែនកន្តោងគង
សម្ភោរនាត ពិណពាទ្យឈឹងផង ស្គរផាស្គរទង

ស្គរទូងស្គរទ័ព ។

ស្គរភ្លេងមេទា ហូទុកស្គរផ្ទា ស្គរមោរផតច្បាប់

ពីងពាំងខ្លុយស្អាល់ ដោយពណ៌សម្រាប់ ខេង្គងសូរស័ព្ទ
លាន់ឮព្រមគ្នា ។
ទើបអស់ព្រះវង្ស ព្រះញាតិនូវអង្គ មន្ត្រីសេនា
ក្រួញក្រាបបង្គំ ប្រណម្យពកជា ពារចូលគ្រប់គ្នា
ចំរើនព្រះស្រី(១) ។
ក្ដួចព្រះហស្តក្សត្រ ពាំពេញរូប្ត ឥសូរសិរសើ
ទើបដោះអាវដាយ រីកក្រាយវន្ទីយ ក្រួញក្រាបបាទបី -
ដងដោះទៀនកំ ។
វែបប្រឹងប្រាណប្រួញ កាន់កន្ត្រញ ខ្ទេនខ្ទំ
តាមបទទៅយុន ខន់គ្ងន់លំនាំ ពារកករំ
បីបទលាកលា ។
អ្នកខ្លះមានខ្មាស ខំទៀនខ្វសខ្វាស ញ៉ាអស់អង្គា
ផងឹតមុខមាត់ ភ្ញាំងភ្ញាត់បាតា ខំពារព
បានតែមួយបទ ។
អ្នកខ្លះវែវប់ មុខស្លុតស្ងៀមស្ងប់ ខប់ចិត្តខំអត់
ក្រួញក្រាបក្រោកទៀន ញ៉ាំដើររន្ធត់ វែកញើសហូរហាត់

១ សិរី ។



លាកលាបរបេញ ។
គេសើចទ្រហឹង អៀនងន់ទ្រមឹង ទឹងចិត្តអាម្មេញ
ខុនណាងពីក្នុង រហង់មើលពេញ សឹងវែបមុខបេញ
ញញឹមសើចសល់ ។
កំបួចគ្រប់គ្នា ទើបបើកក្រយា ស្ងាយស្ងាបតម្កល់
លើសុពណ៌ភាជន៍ ចិញ្ចាចមកដល់ ថ្វាយក្សត្រនិម្មល
ចាំងបួនអង្គា ។
ភ្ញាក់ផ្អាកេងសោយ លើកកិលអណ្ដោយ អណ្ដាប់រៀងគ្នា
ថ្វាយថ្វាត់បិទបាំង ត្រកង់សន្និយា ស្ដេចសោយទទួលជា
ព្រះក្រយាស្ងោយ ។
ទើបអស់មន្ត្រី លើកភោគចំណី មករៀបដាក់ដោយ
មុខឯងទីទៃ លាងវៃផាក្រោយ ដីហាស្ដេចសោយ
បរិបូណ៌ស្កល់ស្កប់ ។
ចាំងបួនព្រះអង្គ ស្ដេចយាត្រាត្រង់ ទតល្បែងមហោស្រព
លោតគុនពេនក្បាល់ ប្រដាល់ប្រតប់ គ្រីវិស័យសព្វ
កញ្ចុងដើតស្បែក ។

ដាំផ្គូនហក់តោ ហក់ដាវរត់គោ មានទាំងតំបែក
ងើយងដល់គ្នា ល្អដាច់ខ្សែក ក្បាច់ស្រួលល្អពេក
សៀមប្អូននាងក្រោយ ។
ពាំស្នែងទន្សោង ស្លព្រ័ត្រយោលទោង ផ្កាគូផ្កាកយ
ល្ហានរបាំ រវាំកែកាយ ប្រៀនប្រួចនិយាយ
ពីពេះស្បូរសម ។
មានទាំងចំបាប់ ស្ទៀកខោគាត់ខ្លាប់ ពង់រូបជាតធំ
ដឹកដៃផ្គូផ្គាប់ ផ្ទឹមផ្ទាប់ទំហំ ឲ្យល្មមស្មូនសម
ចូលក្នុងស្នាមជ័យ ។
ប្រួញប្រាណប្រវេះ តាមដោយចំណេះ របៀបចំនៃ
លូកដៃដល់ដាក់ កន្ត្រាក់វិលវៃ គេចគោះដុំដៃ
ដាល់ដួលស្រទាន ។
ផ្ការដេកនៅដី ផ្ទុយផង់ធូលី ពេញអស់រូបកាន
ខ្លះចូលប្រចាប់ កៀកខ្លាប់ពីខាង ខ្លះលោតវៃពង
ស្ទុះស្ទាត់ស្មើគ្នា ។
- ខ្លះក្រាបក្រាញក្រោម ប្រឹងផ្ទាយទាំងផ្ងោម ទាំដីប្រភ



ខ្លះជាក់ផ្ការប្រាង ចំកោងអាត្មា ពេនព័ទ្ធបាទា
ដោះគេចវិលវៃ ។
ខ្លះនៅពីលើ តាមតែទីងធ្វើ រកកលកែខៃ
ខ្លះលូកខ្លះចាប់ ផ្ទមខ្ទាប់ដល់ដៃ ទង់ទាញទីទៃ
ប្រឹងប្រែប្រះប្រាណ ។
លោតមុខថ្ងាស ក្រោកឡើងខ្ទុសខ្ទាស ដៃបោសខ្លួនប្រាណ
គេសើចទ្រហឹង អ៊ឹអ៊ឹងសព្ទសាខ ពស្ត្រផងគ្រប់ប្រាណ
មើលម៉ាត្រៀបត្រា ។
ខ្លះខុនខ្សឹបខ្សៀវ កកេះកកៀវ បង្ហាញគ្នីគ្នា
ខ្លះឈរចាំទិត ចំអើតអគ្គា ក្លាំងក្ដួចធំស្វា
ប្រហាទាំងមាត់ ។
ស្ដេងស្ដេចឲ្យលេង គ្រប់ពណ៌ជាល្បែង មង្គលការក្សត្រ
ប្រាំពីរទិវា ទឡ្ហាកក្ដាត់ សឹងស្ទូរក្អែងក្ដាត់
លាន់ឮសព្ទសាយ ។
លុះស្រេចការស្អុល បរិបូណ៌មង្គល សាន្តសុខសប្បាយ
មន្ត្រីសេនា យោធាទាំងឡាយ ឡើងគាល់រៀងកាយ

តាមដោយត្រឹក្សក្រម ។

ព្រះពោធិសត្វ ទូវនារីរត្ន សេពសោយសុខស-

ម្បត្តិបានពង្សច្រង់ ឧត្តុង្គឧត្តម ស្តេចចូលបន្ទំ

បន្ទូលត្រាស់ថា ។

ហៃប្អូនទង់វង ស្ងួនអើយចិត្តបង បង់បរយាត្រា

យកទាំងប្អូនស្ងួន ខ្ញុំមខ្ញុនពុំផា ទៅនគរ

ពាកណាសី ។

-បងមើលគំនិត មស្រែកកាបគិត ទឹងក្សត្រអប្រិយ

កាន់ទីងធ្វើស្តេច កលកិច្ចទៀតថ្មី បង់ជីងសេចក្តី

ឲ្យអស់ចិត្តភា ។

ស្រីរត្នឧត្តម នាងថ្វាយបង្គំ ទើបទូលទៅថា

បើម្ចាស់គន់គិត គំនិតស្តេចម្ចា ខ្ញុំឥតបើថា

ព្រមតាមព្រះទ័យ ។

ស្តេចស្តាប់នាងនាថ ត្រើសព្រមខ្ញុំឃ្លាត ទៀងទើបក្សត្រថ្ងៃ

ពីរពង្សផ្តឹមផ្គុំ បរមសុខសេយ្យ លើគ្រៃមាសម័យ

រុងរឿងសោភា ។



# បទព្រហ្មគីតិ

—លុះព្រឹកព្រាងស្វាងស្រេច ទើបសម្តេចព្រះរាជា

នាំនាងនាថលីលា ឡើងគាល់ព្រះបិតាក្សត្រ ។

ទូវព្រះវរមាតា ឱនអង្គាប្រញ្ញប្រណិប័តន៍

ប្រណម្យទូលទៅថ្វាត់ ថាបពិត្រក្សត្រថ្លៃថ្លា ។

ត្រើសត្រង់ទូវព្រះគុណ វិសេសធ្ងន់ឥតឧបមា

ពុំគួរនឹងឃ្លាតឃ្លា ពីព្រះបាទព្រះអង្គទៅ ។

គួរតែខ្ញុំបិតបាន នៅនេះបានឡើងគាល់ហៅ

បំរើសព្វថ្ងៃនៅ លុះអស់ជីពអស់ជន្មា ។

គឺមោះខ្ញុំបង់យល់ បង់ជីងកលគំនិតកា

មស្រុកទិងក្សត្រា ព្រហ្មទត្តចិត្តតិរយ ។

កាន់ទីងគិតកលកិច្ច ធ្វើដូចស្តេចវិញទៀតខ្ញុំ

ខ្ញុំបង់ជីងសេចក្តី ឲ្យភាធ្វើអស់ចិត្តភា ។

ខ្ញុំសូមក្រាបលាទៅ ផ្ញើពង្សនៅក្សត្រថ្ងៃថ្លា

ពុំបរត្រង់មេត្តា អត់ទោសប្រោសសត្វជាខ្ញុំ ។

ស្តេចស្តាប់ព្រះសុណិសា ក្រាបទូលលាជ្រាបដោយដំ-

ណើរនោះទើបបរម-　　ក្សត្រាត្រាស់បន្ទូលថា ។
ហៃបាបុត្តបណ្ដូល　　បាមកទូលសុំក្រាបលា
អាពុកឥតបើថា　　បើកតាមចិត្តប្រាថ្នាប៉ង ។
ចូរបាយកមន្ត្រី　　សេនាពីអាយទៅផង
កំដរបុត្រស្ងួនគ្រង　　គ្រាន់ប្រយ័ត្នប្រយោជន៍ប្រាណ ។
ព្រះពាធិវង្ស　　ស្ដាប់ហើយទូលទៅវិញក្ដាន
បពិត្រខ្ញុំសូមទាន　　សូមតែនាងនាថជាយា ។
នូវសេះអាជានេយ្យ　　ព្រះខ័នជ័យផ្ទុសារថ្វា
យកទៅផងអាត្មា　　ក្រែងក្រីក្រគ្រាន់ប្រស្រ័យ ។
ស្ដេចស្ដាប់រាជបុត្រទូល　　ក្សត្រឥសូរព្រមព្រះទ័យ
បើកបុត្រពីរថ្វាថ្ងៃ　　ពុំឃាំងឃាត់តាមចិន្តា ។
ទើបព្រះវរជននី　　ឱបបុត្រីសោយសោកា
បន្ទូលផ្ដែផ្ដាំថា　　ហៃកូនស្ងួនសម្លាញ់ម្ដាយ ។
នាងទៅនឹងស្វាមី　　ឃ្លាឃ្លាតទូរទើបបានឆ្ងាយ
ទៅនៅនគរនាយ　　ចូរផ្ចិតផ្ចង់ប្រុងស្មារតី ។
ប្រុងប្រាណក្រាបប្រណិប័តន៍　　ព្រះរៀមរត្នជាស្វាមី



តាមដោយត្រឹត្យក្រមស្រី　　កុំឲ្យព្រួយព្រះចិន្តា ។
ហើយកូនកុំបោះបង់　　ម្ដាយលន់លង់យូរឃ្លាតឃ្លា
ម្ដាយមានតែនាងជា　　ថើមបណ្ដាច់បណ្ដូលចិត្ត ។
នាងនាថសោកសឹងសោក　　សែនអរមោក្សអួលអាណិត
អនាថពន់ពេកក្ដាត់　　គិតជននីនូវបិតា ។
បន្ទាទុក្ខស្រាលស្រេច　　ទើបសម្ដេចព្រះរាជា
នូវនាងនាថលុតលា　　វិលវិញមកមណ្ឌលទ័ ។
ផ្ដែផ្ដាំអស់បរិពារ　　ស្រីស្រឹង្គារស្នំនារី
នូវអស់មុខមន្ត្រី　　ដង្ហិតនឹងស្ដេចទៅទូរស្ថាន ។
ស្ដេចឲ្យយកពាជី　　ជាព្រះទីនាំងក្សត្រក្សាន្ត
ចងគ្រឿងស៊ឹងមាសមាន　　តម្លៃឥតឯគណនា ។
-បង្ហៀរនូវឃ្លុំមុខ　　ខ្សែរឹតអុកសឹងសុវណ្ណា
អានកាពមាសមុខពហ៊ុ　　រាយរំលេចសឹងមណីរត្ន ។
វ៉ែកឈ្នាន់ខាន់ដំពង　　ចង្ក្រង់ផងសឹងពិចិត្រ
ខ្សែហាងគុំកែវកិត　　ក្ដីរុងរឿងសមសោភា ។
សំយាកសំយុងខ្សែ　　សោតសឹងតែសុវណ្ណា

ល្អសលាយខៃងទឹបផា ផ្កាដូងដាំសឹងគ្នាយ ។
ទើបក្សត្រតីព្រះអង្គ ប្រដាប់ទ្រង់គ្រឿងពណ្ណរាយ
រុងរឿងឆោមឆើតឆាយ ល្អលើសលែងទិភករ ។
ស្ដេចសៀតព្រះខម្រង់ ខ័នជ័យទ្រង់ដូសិល្បសារ
នាំនាងនាថបវរ ចាកមន្ទីរមណ្ឌលថ្ងៃ ។

## បទកាកគតិ

ក្សត្រក្សត្រីពង្ស លីលាឡើងគង់ លើកដមនោម័យ
គ្រប់គ្របះ ល្អល្អះប្រពៃ ហាក់សុរិយោទ័យ
ចរចួបចន្ទ្រា ។
គួរគង់បើកបរ ទីនាំងអស្សគរ លន់លឿនលីលា
ចេញចាកអំពី បុរីរដ្ឋា ឆ្ពោះទៅសីមា
ពាពណស័ ។
ស្ដេចដោយមាតា ចូលក្នុងឥន្ទា ព្រៃព្រឹក្សទូរទី
លូតលាស់ផ្លែផ្កា ផលាទុំខ្ចី មានរសពិសី
ពិសេសពិសា ។
ស្ដេចដល់ព្រៃស្វាយ នាំនាងឆោមឆាយ ចរចុះយាត្រា



ព្រះនេត្រវៃព ទតព្រៃព្រឹក្សា សំណោះបរបា
ប្រាប់ព្រះប្អូនស្រី ។
ប្អូនមាសប្រសើរ ស្ងួនអើយមាសមើល ស្វាយក្បាលដំរី
ស្វាយចំពុះសេក ស្វាយចេកឥន្ទ្រី ដិតស្វាយបន្ទី
ដុះដោយពណ៌ភ ។
- ប្អូនមើលស្វាយមាស ស្វាយមីងដេរដាស មីងព្រួលសែរដា
មាក់ប្រាង់ស្វាយព្រៃ ក្រាស់ក្រៃគ្រៀបគ្រា តាំងស្វាយរំពា
ស្វាយរមៀតផង ។
មានស្វាយចន្ទុះ ស្វាយកណ្ដុរដុះ ដាសដោយជ្រលង
ស្វាយសង្កើចផ្អុះ ស្វាយសេះពងត្រង់ ស្វាយខាន់ស្ករផង
ស្វាយឥន្ទលាំ ។
ខ្លះទុំអន្ទង ខ្លះជ្រុះបង់ទង ដោយដីដោតដាំ
សេកសោតព្រះទ្រៀវ ខ្វារខ្សៀវនានាំ- គ្នាហើរទៅពាំ
បានបរិភោគ្គា ។
ប្អូនមាសវរវង្ស មើលក្រូចមាក់ប្ញុង សម្រែសំសា
ក្រូចពិនក្រូចចង- សក់ផងនានា ក្រូចឆ្មារក្រូចភ្លា

ច្រើនពណ៌ពេកក្ដាត់ ។

មាសមើលក្រូចព្រៃ ផ្កាពិដោរក្រៃ ទូវក្រូចពោធិសត្វ

ផ្លែទុំរន្ទាល ប្រាស់ប្រាលច្រើនក្ដាត់ ទូវក្រូចបូម៉ាត់

ក្រូចសើចក្រាស់ក្រៃ ។

- មានបេកអំបូង បេកឥតត្រយូង ទូវបេកមហាថ្ងៃ

បេកទួនបេកស្នែង ផុះឯងវិស័យ បេកក្រចកដៃ

នាងទួនបេកផ្កា ។

បេកពងសីហ៍ ផុះដោយទួលទី បេកផេះមហា-

ត្រកាលបេកល័ក្ខ បេកចាក់នានា បេកស្លាបមុខរាំ

ទូវបេកពងមាន់ ។

ដេរដាសដោយព្រៃ ច្រូងប្រាងច្រើនក្រៃ មានផ្លែណាសណាន់

ទុំទែងរន្ទាល ប្រាស់ប្រាលច្រើនជាន់ ជាជួរខែត្រខណ្ឌ

ផុះដោយពណ៌រាំ ។

ស្ដេចទូវដាយា បេះផលាហារ ដោយដងមាគ៌ា

មង្ឃុតគូលេន មាក់ប៉ែនពុទ្រា ខ្នុរណាំងបាយស្រា

ល្ហុងល្មុតត្ពលត្នោត ។



សាច់សិរមោន់មៀន មាក់ប្រាងទុរេន ដូងខ្ទិះអំពៅ

ឈាំងសាតសាវម៉ាវ បង្គាវបង្គៅ ត្រៀលត្របែកព្នៅ

សំពរស្រគំ ។

- ពោនពួចជន្ទូស គុយគៀរព្រីងព្រូស ដុះដោយព្រៃភ្នំ

ផ្លែច្រើនប្រាស់ប្រាល រន្ទាលទែងទុំ ពីរក្សត្រឧត្តម

ស្ដេចសោយស្កប់ស្កល់ ។

ស្រេចស្ដេចឡើងគង់ លើយានរាម- ផ្គលគាប់សួស្ដីសល់

ត្រាច់បរទៀតទៅ សំដៅដួចដល់ ភពវែងយង់យល់

សត្វសត្វនានា ។

មើលមានគជសីហ៍ គជសិង្ហព្យគ្ឃ ក្រាស់ក្រៃត្រៀបត្រា

កែសរកោដ្ឋកុញ្ជរ កេសរសីហា ឧសឧដ្ឋផុំកា

មិគ្រមាំងឆ្នាត់សី ។

ព្រោះព្រៃមាំង មោសខ្ទីងទាំង គោចៀមចាមរី

កីលែនលៀងកា ស្វាន់ណាពាដី នរសិង្ហនរសីហ៍

ដំរីខ្វាងខ្វា ។

ខ្ទ្យងខ្ទ្យាយ ទន្សោងឈ្លូសព្រាយ គោមហិង្ស

បបកស្ទាស្ទាន  ប្រើសក្តាន់សុកភា  ជ្រូកព្រុលប្រមា

ពង្រូលលាក់មុខ ។

- ញៀសំពោច  ឈ្លូសន្ធាប៉ាពោច  កន្ធែនកំប្រុក

បង្កួយដាសក្ការ  ពស់ស្ការថ្ងូនថ្ងុក  វ៉ៃរស្វរុក

កេរន្ទួនិត្យនៅ ។

ស្តេចយល់សត្វម្រឹគ  កៀងគូគគឹក  រួសរកធីស្នោ

បើកបរវិលង  ដល់ដង់ព្រៃជ្រៅ  យល់យក្សានូវ

បក្សីទាំងឡាយ ។

ហិចហើរធៀងនាប  ទន្ទួងទន្ទាប  ទន្ទឹមរៀងរាយ

ដោយមែកព្រឹក្សព្រៃ  ក្សត្រថ្ងៃពណ្ណរាយ  បន្ទួលប្រាប់ប្រាយ

ព្រះប្អូនពុំងា ។

ស្ងួនអើយមាសមើល  បក្សាជង់ហើរ  ដង្ហែរៀងគ្នា

សេករសោមបណ្ឌិត  នៃបនិត្យសារិកា-  កែវកោកិលា

កុកក្រកគ្រាងគ្រែង ។

ដប់លាយសៀនឃ្មៀន  ដដែតជើងទៀន  រន្ទួបព្រលេង

ប្រមង់ពញ្ញាក់  ទ្រមាក់ខ្វាខ្ទួន  ស្ទាំងពាក់កន្សែង



ដុំដែកទុកទ្រូ ។

- សម្បុកចំពាំង  ស្ទឹកលោតដោចស្បាំង  ខែលខេងហូពូ

ចចាតប្រឡៃ  ព្រាបព្រៃប៉ាគូ  ករវិកសត្វា

ចាបពូកពូម៉ា ។

មាសមើលហោមហង្ស  មយូរពេនពង់  ចាកចាន់ផុលីការ

ដីវកដីវក  ក្រៀលក្រាកក្រសារ  តាដកអកអា-

អូតឡូស្ទឹក ។

ប្រចៀចចេកទុំ  ចៀបកប្បាសត្ថម  ពពូលពុះទឹក

លលកលលេ  រំពេប្រវឹក  មាន់ទោរមាន់ទឹក

ស្មោញអន្ទក់ខ្មៅ ។

មាន់ព្រៃព្រវែក  គ្រចៀកតាំខ្វក  ព្រហីតស្ទិតរៅ

ល្វាចេកប្រចៀវ  ទៀទៀវតារៅ  ទីទុយមៀមនូវ

ផ្ទីចឆ្កៀលខ្យង ។

ក្ងានក្ងោក  ក្ងបោ៉លគោក  នោលត្រយង

សាសេះសេះលាវ  ផោវកកកង-  កេងកុកត្រសង

ត្រសិតហើរហិច ។

នាងខ្លួនក្អែកល្អាត គូកគល់ងក្នាត ត្រុំត្រដេវរុំច
កន្ធុបស-ក ចាក្រពាកស្តេច- គូលីតប្រពេច
ចុងទោមទទា ៗ
បរគាវចិន្ទោ អង្គិតកុលដោ អង្គុចឥន្ទ្រា
សេកយារសេកអាត់ ប្រើនក្តាត់ត្រៀបត្រា កូមរកូមក
ត្រឹបកេសរកើ ៗ
ស្តេចទតបណ្តើរ ដោយផ្លូវដំណើរ ប្រាប់ព្រះអូនស្រី
ខែងខំបើកបរ បររពោធិ ដល់ឆ្នេរដលធី
ទឹកពកត់ពុំជ្រៅ ៗ
ស្តេចបន្ទាស់ធ្ងន់ សមុទ្រទម្ងន់ ពីនោះទៀតទៅ
យាត្រាត្រាច់ត្រង់ តម្រង់សំដៅ ដល់ស្រុកលំនៅ
បានធម៌មាតា ៗ
ពីរពង់ក្សត្រថ្លៃ ចុះចាកអាជានេយ្យ ឡើងលើត្រីហា
ជូនចាស់ស្រាក់ស្រួល សាគស្នូរក្សត្រា ស្តេចប្រាប់ដោយនា
ដំណើរកោរគល ៗ
- លុះសព្វសេចត្រេច ជូនចាស់ស្តាប់ស្តេច អរឥតធ្លឹមដល់



ស្រូវរៀបអាហារ ក័ស្តុការគោដន៍ផល ថ្វាយក្សត្រនិម៌ល
តាំងពីអេដ្ឋា ៗ
ស្តេចសោយស្កប់ស្កល់ ផ្ទុំនៅមណ្ឌល បានធម៌មាតា
លុះព្រឹកក្សត្រានស្រេច ស្តែនស្តេចលាគលា ឆ្ពោះទៅចំការ
ទីដែលនិត្យនៅ ៗ
អ្នកស្រុកផងយល់ ក្សត្រថ្លៃនិម៌ល នូវព្រះអូនពៅ
ទ្រង់គ្រឿងរង្គាល ប្រាស់ប្រាលផ្អិនផ្អៅ គូគង់នៃបនៅ
លើសេះអាជានេយ្យ ៗ
សឹងតន់គិតធ្ងល់ ថាចៅគោគុល ទុគ៌តក្រៃក្រ
បានសេះពីណា លោកាប្រពៃ តាំងគ្រឿងមាសម័យ
ថ្ងៃឥតគណនា ៗ
សឹងសរសើរសល់ ព្វាលេចដឹងដល់ គាមគោផកជា
មេស្រុកកំណាប ចិត្តកាចឫស្យា តាំងចងវេរ
និងព្រះពោធិ ៗ
ដើរមកមើលយល់ ក្សត្រថ្លៃនិម៌ល ទូវនាងនារី
វិលវិញមកដល់ មណ្ឌលបានទី បានតាំងពាជី

ទីនាំងថ្ងៃញ៉ា ។
ទើបមេស្រុកទៅ ដល់ក្បែរកម្មៅ ព្រហ្មទត្តពាលា
រឹះរកកលគិត គំនិតមុសា- ក៏ទរៀបទូលថា
បពិត្រក្បត្រថ្ងៃ ។
ឥឡូវនេះហៅ គោគកុលបេញទៅ· បាត់យូរលង់ថ្ងៃ
សមទៅអន្ទន ក្បត្រផងដទៃ មកក្បត់ក្បត្រថ្ងៃ
ពិតពុំឃ្លាតឃ្លា ។
វិលមកបានទាំង អស្ត្រទើនាំង បញ្ឆិះកិរិយា
ខ្ញុំបានដើរទៅ យល់នៅចំការ មើលឫកយល់ជា
ប្រែចិត្តទីទៃ ។
បើព្រះអង្គព្វាយ ប្រហែសអត់ឲ្យ ទុកនៅក្នុងផ្ទៃ-
ក្រោមក្រែងក្រក្រោយ សូមឲ្យក្បត្រថ្ងៃ ផ្តាញ់ឲ្យក្ស័យ
ជីវិតទើបជា ។
ស្តេចស្តាប់ទទួល តាមគោជកទូល ត្រេកត្រាស់ទៅថា
យើងឲ្យទៅយក ហៅមកយល់ជា មាណពនោះវា
ពុំមកដូចចិត្ត ។



បើឲ្យសេនា ទៅចោមចាប់វា សម្លាប់ជីវិត
យល់ជាពុំបាន វាមានសិល្បសិទ្ធិ ច្បុះយើងនឹងគិត
ដូចម្តេចក៏ជា ។
ទើបតាមគោជក ជាហៅមឿងស្រុក ទូលទៅទៀតថា
បពិត្រព្រះអង្គ សូមទ្រង់ចិន្តា ឲ្យអស់សេនា
បរពលទាំងឡាយ ។
ទោះចិនចាមជ្វា បាក់ងលន្ទា បរទេសសែសសាយ
លើកទៅចោមចាប់ សម្លាប់ខ្លាត់ខ្លាយ កុំគិតមើលងាយ
ប្រហែសទីងវា ។

## បទពំនោល

កាលនោះព្រហ្មទត្តពជា ស្តេចស្តាប់វាចា ពាក្យតាមគោជកក្រាបទូល។ ត្រើសព្រមព្រះទ័យជួបចូល ក្បែណកក្បត្រឥស្សូរ បន្ទូលត្រាស់ប្រើសេនា ។ -ហៅចេញបរពលអាសា(១) ស្រុកទំម៉្ហា ឲ្យបានចូលមកឆាប់ ៗ។ អាមាត្យបត់បាទស្តែងស្តាប់ ទទួលបង្គាប់ បង្គំប្រណម្យលុតលា ។

១- ពលដែលមានចិត្តស្ម័គ្រយកអាសា ។ តែបើដាក់ជា «ពលអស្សា» ក៏ងទពសេះហោក់ ឆ្ងួចជាគួរជាង ? ព្រោះកងទ័ពសម័យបុរាណមានងគី កងទ័ពដំរី, សេះ, រទេះនឹងថ្មើរជើង ។

បរចេញប្រាមប្រាប់គ្នីគ្នា  ទាហានអាសា  យាត្រាប្រញាប់បពេល ៗ
ប្រជារាស្ត្រក្នុងមណ្ឌល  ខេត្តខណ្ឌសកល  ពាកណាសីសីមា ៗ
ករកាន់គ្រប់គ្រឿងសស្ត្រា  បួតបង់កាថា  ប្រទាលគេជះគេផង ៗ
-ពាក់មួកពាក់អាវគ្រោះផ្ទង់ ប្រដាប់ការអង្គ ព្រយោជន៍ប្រយ័ត្នប្រុងប្រាណៗ
ស្រេចចូលមីរមូលមកថ្កាន ដល់មុខព្រះលាន ប្រកិតអាវុធគ្រៀបត្រា ៗ
កាលនោះព្រហ្មទត្តរាជា  ស្តេចឲ្យយកបា  ដំរីទីនាំងនិរភ័យ ៗ
បង់គ្រឿងកញ្ចូងមាសម័យ  ភ្ញីផ្ទុកប្រពៃ  ពិចិត្រសឹងគ្រឿងដាំដាក់ ៗ
ក្បាច់ក្បាំងផ្គង់ខ្សែឆ្នាក់  ផងក្រពាត់ពាក់  ប្រវាក់មាសមានស្មើ ៗ
-ស្ពាប់មុខស្រោមក្តុំដំរី  សឹងមាសមណី  កង្វេរសឹងរត្នបេទា ៗ
ស្តេចឲ្យរៀបពលយោធា  ទាហានអាសា  ចេញជាចតុព្យូហ៍យុទ្ធ ៗ
ស្រួចបែកឆ្វេងស្តាំមោះមុត  ណាន់ណែនប្រាកដ  ប្រកបដោយឡែកទីទៃ ៗ
សេនាកូមាននិរភ័យ  សឹងកាន់ទង់ជ័យ  បញ្ជរបញ្ជប់ត្រាត្រៀម ៗ
អណ្តាប់នោះសោតសឹងសៀម  ពាយរៀបមេរៀម  ដាក់លើដំរីផ្គងផ្គូ ៗ
-សេនាខ្មែរសឹងកាន់ធ្នូ បេះបាញ់ត្រង់ត្រូវ មុតមែនកូនស្នាតតម្រង់ ៗ
អណ្តាប់នោះចិនហៃហាង  រីងរូសទ្រមង់  ករកាន់ដាវឌ្វីខែលស្រាង ៗ
បែកស្តាំសោតសឹងបាពាំង  ករកាន់ស្នាប់បាំង  ម្នាម្នះក្រៃលែងមហិមា ៗ



អណ្តាប់នោះសឹងកូឡា  កាន់សំសែងរ  ត្រីពញាមពន់ពេក ៗ
អណ្តាប់នោះសេនាខែក  កាន់សេឡោស្បែក  ទូរដាវកូនស្រាលងា ៗ
-បែកឆ្វេងសោតសឹងសេនា យួនយកអាសា ករកាន់កាំភ្លើងស្នុកពេង។
សេនាថ្កាតាត្រកអោង  ជួតក្បាលសំពោង  ករកាន់ខ្ទូរក្រីសគ្រប់ដៃ ៗ
សេនាចាមចិនហានក្រៃ  កាន់កាំភ្លើងដៃ  បញ្ជរប្រូង៍ប្រាង់ប្រទាស់ ៗ
ចំពទូលស្នាស្កាត់ណាស់  កាន់កាំភ្លើងរះ  រេបរបៀបបីសំពៀង ៗ
សេនាជប៉ុនខ្ចះខ្ចៃ  ករកាន់ដាវវែង  គ្រីតឃើញគហ្មារ ៗ
-អណ្តាប់នោះសេនាលាវ កាន់លំពែងសាវ ចាមចែងចុងទ្វាល ៗ
សេនាមនទៅកណ្តាល  ជិតដើងគជសារ  គជេន្ទ្រទីនាំងក្សត្រា ៗ
កាន់ស្នែងក្របីងងា  ខ្លះកាន់គ្រទា  ខ្លះកាន់ដបខចាំបៃរ ៗ
ខ្លះកាន់តូរ្យតន្ត្រីក្រ-  ស័ន្ទសឹងដើរហែ  អណ្តាប់អណ្តោយរៀងគ្នា ៗ
ទើបក្សត្រព្រហ្មទត្តរាជា  ទ្រង់ពរពស្ត្រា  ប្រដាប់អស់អង្គឥន្ទ្រិយ ៗ
- ទ្រង់គ្រោះពេជ្ររត្នមណី ឡើងគង់ដំរី  ទីនាំងប៉ែកបាំងក្លស់ក្លំ ៗ
ស្តេចឲ្យដំរីសោរសេម  រូបកង់ធាត់ធំ  ចុះប្រេងហូរហៀរផល់ក្ទុក ៗ
ដាក់ឲ្យទៅតាមកោដក  ជិះបរនាំមុខ  ទីនាំងព្រះបាទក្សត្រា ៗ
ស្តេចលើករហ័ពលយោធា  ឆ្ពោះត្រង់ចំការ  ព្រះពោធិសត្វនិមិល ៗ

ដល់ស្រេចស្ដេចឲ្យអស់ពល បោមជុំមណ្ឌល ប្រាំពីរជាន់ជិតគ្រៀបគ្រា ៗ
-ហោរាហាខ្លួរខ្លារមហិមា ទើបស្ដេចត្រាស់ថា ហៃបៅភោគកុលកុមារ ៗ
បៅនាំកិរិយាត្រេកអាល ចេញទៅគិតការណ៍ គំនិតទីងក្សត្រទៃ ៗ
បៅយកទ្រព្យមានដំឡៃ ទៅថ្វាយប្រស្រ័យ យឹកយោនអន្ទងមកក្បត់ ៗ
យើងមានដំណឹងប្រាកដ យើងនឹងធ្វើគត់ សម្លាប់បៅនេះឥឡូវ ៗ
ផ្ចិតបៅចេញជាសត្រូវ ពុំគួរទុកនៅ ឲ្យរស់ជីវិតជន្មា ៗ
-កាលនោះព្រះពង្សព្រឹទ្ធា ស្ដេងស្ដាប់វាចា ស្ដេចព្រហ្មទត្តតិរ្ឆិយ ៗ
ព្រះអង្គឥតក្ដុកភ័យពិ- សឹកដូចកេសរី សីហនាទចេញពាក់គុហា ៗ
មានព្រះបន្ទូលទៅថា ហ៊ឺយក្សត្រមោហា អង្គអន្ធពាលឆោតធុក ៗ
ដោយតែពាក្យគាមភោជក នាំទៅនរក ពុំគិតបាបពៀរវេរ ៗ
កេកលនឹងធ្វើទោសា ឲ្យយើងមរណា នឹងយកកិរិយាយើងទៅ ៗ
-ទាល់តែនានានាថពុំនៅ នាងវិលវិងទៅ ដល់ព្រះបិតាក្សត្រក្សាន្ត ៗ
យើងត្រាច់ទៅតាមព្រៃប្រាណ យកនាងមកបាន អំពីព្រះវរបិតា ៗ
ឥឡូវលើកពលយោធា មកបោមប្រាថ្នា ចង់ចាប់សម្លាប់យើងទៀត ៗ
កេកលមុសាផ្ទាស់ផ្ទៀត ថាយើងបែរបៀត ចូលនឹងសត្រូវដទៃ ៗ
ចូរចេញថយទៅវៃ ១ បើចាំនៅក្ស័យ ព្រះជន្មឥឡូវនេះផុត ៗ



-កាលនោះព្រះបាទព្រហ្មទត្ត ស្ដាប់ហើយក្រោធក្ដាត់ ចាត់អស់ពលយោធា។
បូរបោមចាប់យកតួវា មកកាត់សិរសា ឲ្យបានឥឡូវឆាប់ ១ ៗ
អស់អង្គសេនាស្ដេងស្ដាប់ រត់ចូលប្រញាប់ តាមដោយព្រះរាជអាជ្ញា ៗ
ឯអង្គពូជពង្សសាស្ដា ឥតគិតភយា ស្ដេចយកព្រះកៅទណ្ឌជ័យ ៗ
ទណាក់ដំឡើងកាត់រៃ ព្រះហស្ដក្សត្រថ្វៃ ថ្វៃងថ្វាត់បន្ទោះចេញទៅ ៗ
-លាន់ឮក្រើកក្រៀលក្រៅ ខ្ទាំងលាំនៅ កណ្ដាប់នៃចក្រវាឡ ៗ
ដូចសែនរន្ទះមហិមា បាញ់ចុះព្រមគ្នា ហាក់ដូចនឹងផ្លាប់ប្រឹថពី ៗ
ពុះពោរផន់ផោរដល់ធី សុមេរុគិរី កក្រើករំពើកពេកក្ដាត់ ៗ
កាលនោះឯអង្គមហាក្សត្រ ព្រះបាទព្រហ្មទត្ត នូវគាមភោជកអប្រិយ ៗ
កិតធ្លាក់ពីលើដំរី ដួលដល់ផែនដី ក្សិណក្ស័យជីវិតជន្មា ៗ
-ធ្លាក់ទៅសោយទុក្ខវេទនា នៅនរកមហា- តាបន៍ដល់កន្ទះកល្បគត់ ៗ
អស់ពលផងកិតរន្ធត់ ស្ទើតស្ទាំងស្ទន់ស្ទុត ដួលដេករណែលត្រៀបត្រា ៗ
អស់មុខមន្ត្រីឯណា ដែលគិតនឹងមហា- ក្សត្រាសិងក្ស័យជីវិត ៗ
ឯណាពុំបានចូលគិត មូលមួយគំនិត គំសឹងរួចរស់ជន្មា ៗ
ក្រោកឡើងញរអស់អង្គា គិតភ័យតក្កមា បង្គំប្រណម្យទូលទៅ ៗ
-បពិត្រអម្ចាស់ជមបៅ សូមទានទ្រង់នៅ- មេត្តាករុណាអត់ទោស ៗ

ឲ្យមានជីវិតសន្តោស   អាសូរប្រោណប្រោស   ឲ្យគង់ជាខ្ញុំតទៅ ៗ
ទើបព្រះតូចផពង្សពុទ្ធផៅ   បើកបន្ទូលទៅ   ថាហៃអស់មុខមន្ត្រី ៗ
គ្រប់គ្នាតើមានទោសអ្វី   កុំភ័យទៅថ្វី   អញសោកពុំយកទោសា ៗ
មន្ត្រីត្រេកអរគ្រប់គ្នា   ផ្សិតស្តេចមេត្តា   ប្រោសទុកជីវិតឲ្យគង់ ៗ
-ទូលថាបពិត្រព្រះអង្គ   អម្ចាស់ថ្លៃទ្រង់   ព្រះគុណព្រះករុណាណាស់ ៗ
ឥតអ្វីផ្ទឹមគុណក្រៃក្រាស់   អញ្ជើញអម្ចាស់   ចាំងពីរទៅសោយរាជ្យរម្យ ៗ
ជាឥស្សរអស់យើងខ្ញុំ   គ្រងផ្ទៃក្រោមក្រម   ពិតពិតក្តិកស្ត្រផង ៗ

## បទកាកគតិ

- កាលនោះព្រះអង្គ   អំបូរតូចផពង្ស   សាពៅជ្បាស់ប្បង់
ស្តាប់ពាក្យសេនា   យោធាពលផង   អញ្ជើញទៅគ្រង
រាស្ត្ររាជរដ្ឋ ៗ
ស្តេចព្រមព្រះទ័យ   ទើបក្សត្រជៀសជ័យ   ទូវនាងជាយា
បែរបើកបន្ទូល   មធុរត្រាស់ថា   ហៃអស់អង្គអា-
មាត្យមុខមន្ត្រី ៗ
បើអស់គ្រប់គ្នា   ចង់ឲ្យយើងជា   ក្សត្រាធិបតី
ចូរសង់មន្ទីរ   ជាគ្រឹះថ្មោងថ្មី   យើងពុំនៅទី



ដែលស្តេចព្រហ្មទត្ត ៗ
មើលបានទទួល   ឯណោសមគួរ   សមជាទីក្សត្រ
រិះគិតស្រួសរៀប   រណ្តាប់ថ្វាត់ ១   កាត់តែងបាប់ចាត់
បែងចែកដោយឆារ ៗ
ជ្រើឲ្យសមគួរ   ហើយមកទទួល   អញ្ជឹងការយា
មន្ត្រីផងស្តាប់   បង្គាប់ក្សត្រា   ទើបតែងដោយឆារ
ដោយមុខទីទៃ ៗ
ខ្លះក្រាបលុតលា   បេញ្ចរម្ហា   រើសរកឈើព្រៃ
ខ្លះដេកចាំនៅ   គាល់ហៅក្សត្រថ្ងៃ   គ្រឿងគ្រប់ដោយដៃ
ចាំក្សត្រពីរពង្ស ៗ
- ខ្លះដើររកមើល   ទីភូមិប្រសើរ   គួរជាស្តេចគង់
យល់ទីមួយធំ   សួស្តីសមគួរសង់   មន្ទីរទើបទង់
ខ្សែស្រិនចុះបោះ ៗ
ភស់ចែកដោយឆារ   កំណាន់ខាន់ការ   ឥតឯចន្លោះ
ប្តូកចាំងប្រាស់ប្រាប   ឲ្យរាបស្មោស្មោះ   លុះល្ងាចវិលផ្ទោះ
ទៅផ្ទះទីទៃ ៗ

ហេតុតែសម្ភារ ពន្សព្រោះពិសា- ពេជ្រពុទ្ធញាណញេយ្យ
ក្តៅដល់សាសនា ឥន្ទ្រាថ្វាថ្លៃ ដូចភ្លើងវិស័យ
ពេលកលមហិមា ។
ព្រះឥន្ទ្រប្រែគ្រ្ត បែរបើកទិព្វចក្សុ សហស្សនេត្រា
ទតយល់ព្រះអង្គ ពួតពន្សសាស្តា ទូរសុខុមា-
លទ្ធាទេវី ។
បរិបូណ៌បានជា ស្តេចស្តែងនៅនា ពារាណសី
ពុំមានមន្ទីរ ជាកេរ្តិ៍ហោនផ្ទី សមគួរជាទី
លំនៅក្សត្រា ។
ទៀងទើបព្រះឥន្ទ្រ ចមរៅទេវិន្ទ្រ បរមទេពា
មានព្រះបន្ទូល មគួរត្រាស់ថា ហៃពិស្នុការ
បាចូរចុះទៅ ។
សាងសង់ប្រាសាទ ទាំងថស្អាងស្អាត សឹងមាសសន្ធៅ
ដាំដាសាកយគ្គ ថ្វាយក្សត្រចមទៅ ទាំងពីទិត្យនៅ
ពារាណសី ។
កត្តុកំពែង កែវគិតតាក់តែង ឲ្យសមសោភី



ឲ្យបានរួចក្នុង កម្មដករាត្រី យប់នេះកុំបី
ផ្សរផ្សងវេរ ។
ពិស្នុការស្តាប់ ទទួលបង្គាប់ សម្តេចឥន្ទ្រា
ក្រញូងក្រាបប្រណម្យ បង្គំលុតលា នាំអស់ទេវតា
ទេវបុត្រច្រើនក្រៃ ។
ហោះចុះមកត្រង់ ទីភូមិនឹងសង់ មន្ទីរក្សត្រថ្លៃ
គន់គិតធ្វើជា ប្រាង្គប្រាសាទជ័យ ទាំងថត្រៃឈៃ
ត្រឈឹងខ្ពស់ខ្ពង់ ។
សឹងមាសចិញ្ចាច ចំពែងត្រដាច ត្រដែតជោមដុង
ដាំដាក់ត្បូងកាយ ឆាឆាយយល់យង់ គានឃ្លាយចមចុង
កែវកែមរចនា ។
សក្តិសមកំពូល កំពស់ត្រៃសូល៍ ដង្ការដេហា
មុខនាគឆ្លាក់ឈ្លប រំលេចរចនា កែមកែវមុក្តា
មកេតកាល់កិត ។
រទូតរនាំង រនាបជញ្ជាំង ចិញ្ចាចកាយគ្គ
រៀបរៀងរំលេច ដោយក្បាច់ផាសជិត ផាសផេរប្រណិត

ប្រកបស័ក្តិសម ។

ហោជាងក្បូរក្បាច់ ឆ្លាក់ឆ្លៅឆ្លុកឈ្លេច ជាទេពប្រណម្យ
កាន់ភ្ញីវល្លិវណ្ណ ពាក់ពន្លត្រៀវគ្លុំ ក្លែងក្លាយបន្សឹ
ជារូបពានរ ។

ប្រែប្រឹងប្រាណប្រញ្ញ កាងកក្ញញ កាន់ភ្ញីឈានឈរ
ក្លាយជានរសីហ៍ ដំរីនាគនរ ក្លាយជាកិន្នរ
ររាំកាន់ភ្ញី ។

· កញ្ចាំងវែងមួយ សាពយពករយ រៀបពយមណី-
ត្នរៀនរំលេច ដោយក្បាច់សោភី ឆ្លាស់ឆ្លុះរស្មី
ភ្លឺផ្លេករព្រាងព្រាយ ។

សសរស្តម្ភស្តង សឹងមាសតាន់វែង ល្អល្អះពណ្ណរាយ
ក្រោមស្លឹកខ្នុរខ្នាប់ ប្រដាប់ក្បៀមក្លាយ ជាភាពរៀងរាយ
គ្រប់កបចុមា ។

ដាសដំរំលេច សឹងស្លូវកាន្តពេជ្រ កែមកែវមុក្តា
ពពាលរត្នរាយ ពិតាបេតាក វៃបវៃពទូរ្យទា-
ទឹមទិព្វស្រស់ស្រ៊ល ។



ត្រកង្លាស់មរកត កែមកាល់បុស្សរ-(១) ទុមរាគទឹកវិល
ពិទូរ្យជោតិ រស្មីស្រស់ស្រិល វែងបទ្ធមហានីល-
រត្នរាយរេខា ។

ក្រឡាបន្ទំ វែងទិព្វមុត្តម សឹងរូបយក្សា
កុម្ភណ្ឌគ្រុឌគ្រប់ ស្ភាញស្ពប់បុប្ផា កែកាងហត្ថា
ប្រែប្រឹងទ្រាំទ្រ ។

- ល្បិកផ្កាប់ក្បាច់ពេជ្រ ល្អសលាយរំលេច ទងទាក់ទៅមក
ជាភ្ញីពេនពាក់ ឆ្លាយឆ្លាក់ល្អះល្អ ក្លែបក្លាយជាជរ
ពិតានសំយុង ។

ក្រឡាទីនាំង កោសកលបល្ល័ង្ក ពានទ្រទ្រង់
គ្រប់កល្បុកឆ្លាក់ ដាំដាក់រត្នរុង- រឿងរំលេចក្នុង
បម្លាក់ព្រោងព្រាយ ។

មានស្វេតឆ័ត្រ ប្រាំពីរត្រួតរត្ន បើកបាំងរៀងរាយ
គ្រប់វែគ្រមាសមាន ពិតានរំកាយ រំភើយត្រសាយ
ត្រសាក់ស្លួស្តិ៍សម ។

កន្សោមតាខ្នុផ្កា សំយុងមាលា រំយោលដិតជុំ

---
១ អានថា: បុសបត់ - ទុំភកទឹកវិល ។

ខ្នើយខ្នល់ព្រះក្រាល កម្រាលចៀមចំ ពូកពាសព្រែព្រំ
ប៉ាក់ប៉ាន់សុវណ្ណ ។

ផ្សរផ្សំកេងកន កេងម្សៅសោតមាន កេងយាមនាលិកា
កេងដាក់ដំរី ពាជីរថា សាល័យសាលា
បញ្ចង់សឹងសម ។

- មានផ្ទះមណ្ឌប ពិសេសគ្រាន់គ្រប់ កនហាលធេងធំ
កាំងខាំងកាំងខណ្ឌ ច្រើនជាន់ជិតជុំ ផ្ទះស្រីព្រះស្នំ
រៀបរៀងកល់កយ ។

កំពែងកែវកិត ប្រាំពីរជាន់ជិត ជុំជាបន្ទាយ
ខ្លះនាងប្រាល ទ្នាលពព្រាយ ពព្រោងក្ដីសាយ
ក្ដីសព្វទិសា ។

មានតាំងមណ្ឌប ដាក់ដោយទ្វារគ្រប់ មុំមានបញ្ជា
ដោយមុំខាំងខណ្ឌ មានចន្ទធាយា មានស្រះស្រង់ថ្វា
សម្រាប់ក្សត្រថ្វៃ ។

ឃ្លាំងមាសឃ្លាំងប្រាក់ ឃ្លាំងព្រែសុភ័គ កាសាយកោសេយ្យ
ពស្ត្រាទិព្វទេស ពិសេសច្រើនក្រៃ ពេញតាំងឃ្លាំងជ័យ



ឥតឯគណនា ។

ព្រះពិស្ណុការ ជាងបេះបេនា តាក់តែងប្រាង្គប្រា-
សាទដូចជាបាន ពិមានសួគ៌ា ស្រុតស្រុតមកនា
ភូមិកតផែនដី ។

សរសេរអក្ខរ នៅខ្លោងទ្វារថា សម្ដេចកោសិយ
ប្រើពិស្ណុការ សម្មាមកពី សួគ៌សង់ទិព្វទី
ប្រាសាទសុវណ្ណ ។

ថ្វាយក្សត្រពីរពង្ស អញ្ជើញស្ដេចគង់ ក្សេមក្សាន្តចិន្តា
ហើយហោះវិលវិង ត្រៃត្រឹង្សសួគ៌ា ទូលព្រះឥន្ទ្រា
សុសសព្វសេចក្ដី ។

លុះព្រឹកស្រាងស្រេច សូរ្យសែងឡើងលេច ពីបូព៌ទិសទី
អស់អគ្គសេនា យោធាមន្ត្រី ភ្ញាក់ឡើងពី
ដំណេកនិទ្រា ។

រលះរលាំង លុបលាងមុខមាត់ ខ្ពុរមាត់ធ្មេញ
ហើយហៅកូនក្មួយ តាមក្រោយយាត្រា ចេញចាកគ្រឹហា
ទៅធ្វើពុធការ ។

មៀងមើលទៅត្រង់ ទីដែលនឹងសង់ មន្ទីរក្ងបាល
យល់ប្រាសាទមាស ឧកាសរន្ទាល បញ្ញាច្រើនប្រាល
កែមកែវព្រោងព្រាយ ។

- ភាន់ភាំងផ្អូកផ្អើល ហៅគ្នាមៀងមើល អំពីចម្ងាយ
ជារ៉ុយគ្នាយើង ធាប់ឡើងមកអាយ មើលទៅឯនាយ
ភ្ញីភ្ញីដល់ម៉្លេះ ។

ចៅខ្វះលលើ ជាភ្លើងឆេះឈើ ទើបភ្ញូដូច្នេះ
នាយដេរទៅថា ម្ដាយអាស្លាប់ប្រេះ ភ្លើងអង្គុលឆេះ
ភ្លឺផ្សេកត្រកាល ។

កូនក្មួយខ្វះឆ្លើយ ទៅថាលោកអើយ ភ្លឺដូចមេឃផាល
ផុំ ៗ ដូចផ្កាយ ព្រោងព្រាយរន្ទាល អស្ចារ្យត្រកាល
ចំឡែកមហិមា ។

នាយថាអាមាត្យ មើលហាក់ប្រាសាទ ប្រសើរមិនថា
ជុំវិញតូច ៗ ហាក់ដូចបញ្ញា អាតាមតែថា
ពាភ្លើពភ្ញាក់ ។

សង្ឃឹមភ្នែកអា ឲ្យមើលគ្រប់គ្នា ដូចប្រើមនុស្សខ្វាក់



ចាញ់ទីងភ្នែកចាស់ ឆ្ងាយណាស់ដៀងជាក់ អញមើលយល់ហាក់
ប្រាសាទសុវណ្ណ ។

- មន្ត្រីតូចធំ រូតរេតបំព្រំ បំព្រោងគ្រប់គ្នា
បែកញើសហូរហាត់ រន្ធត់អង្គា ដល់មុខនាគទា
ខ្វាងទ្វារកំពែង ។

មើលយល់អក្ខរា សរសេរទុកថា គឺព្រះឥន្ទ្រឯង
ប្រើពិស្ណុការ សម្មាតាក់តែង ធ្វើថ្វាយស្ដេចស្ដែង
គួរគង់ក្សេមក្សាន្ត ។

មន្ត្រីទាំងឡាយ អរឯងរីកពាយ ពេកពន់ប្រមាណ
សឹងសរសេរថា ឧប្បុញ្ញបុកណា សំណាងយើងបាន
ម្ចាស់ថ្លៃមានបុណ្យ ។

ពីដូនពីតា ពីទួតលួតលា រៀងរាជ្យពីមុន
ឥតអង្គក្សត្រា ឯណាមានបុណ្យ យើងមានភ័ព្វពន់
ភ័ព្វពេកមហិមា ។

បានជួបទីងម្ចាស់ មានបុណ្យក្រៃក្រាស់ ឥតឯគណនា
យើងនឹងបានសុខ ទៅមុខគ្រប់គ្នា ដោយបារមីមហា-

ក្សត្រថ្លៃថ្កើងថ្កាន ។

ឥតទុក្ខឥតភ័យ ឥតស្តេចដទៃ ណាមករបៀតបាន
ទើបនាំគ្នាដើរ ចូលមើលសព្វឋាន ប្រាសាទមាសមាន
បន្ទប់ខ្ចាត់ខ្ចែង ។

ឃ្លាំងប្រាក់ឃ្លាំងមាស ឃ្លាំងសំពត់ពាស ពោរពេញគ្រប់ល្វែង
ព្រឹព្រួបពេមា គ្រប់គ្នាស្ញប់ស្ញែង កោតបេស្តាស្តែង
លើសលើលោកា ។

មន្ត្រីអបអរ នាំគ្នាចេញចរ ទៅទីសាលា
ខ្លះរត់ត្ដោះទៅ លំនៅក្សត្រា ទូលព្រះរាជា
ឲ្យជ្រាបជាមុន ។

ខ្លះទៅប្រញាប់ ដង្ហោយប្រាមប្រាប់ រាស្ត្រប្រជាជន
ចាមចិនក្លួយតាំង បារាំងជប៉ុន យួនលាវសៀមល-
ន្ទាតាំងភូមា ។

ករកាន់លំពែង ដាវខ្លីដាវវែង កាំភ្លើងធ្នូស្នា
ត្រូវតន្ត្រីត្រែ ដង្ហែក្សត្រា ភ្លេងចិនភ្លេងជ្វា
ភ្លេងសៀមមហោរី ។



- ទីនាំងគជសារ ចងគ្រឿងរចនា សឹងមាសមណី
គជេន្ទ្រប្រាសាទ ព្រោងព្រាតរស្មី ស្ទាបមុខសោភី
ដង្គន់ខ្សែឆ្នាក់ ។

ក្ដុកង-ស័ក្តិសម សុទ្ធសឹងចង្កុំ- មាសមានចម្លាក់
ចម្លែកល្អះល្អ ដងក្រពាត់ពាក់ ខ្សែយោងប្រវាក់
ប្រវាត់រង្សី ។

ទីនាំងអស្សពាហ៍ អានមាសមុខកហុំ រុងរឿងរស្មី
ខ្សែហាងតួបតាំង បុស្សនាំងថ្ពាងខ្ចី ឃុំមុខមណី
កែមកែវយល់យង់ ។

រឹតអុករឹតរថាង ខ្សែហាងខ្សែហោង ដោតដាក់ចង្ក្រង
បង្ហៀរប៉េកប៉ាក់ ដាំដាក់ត្បូងផ្លង់ ខ្សែឈ្នាន់សំយុង
សំយាកងើតឆាយ ។

ទីនាំងកជរថ ទឹមសេះសសុទ្ធ ពិពណ៌ពណ្ណរាយ
ទ្រពងធៀរធ្នង់ កាំកង់ប្រែកក្រាយ ដាក់ដាំរត្នរាយ
រលេចរចនា ។

- ចន្លោលសឹងពេជ្រ ផ្កាក់ផ្កាំរលេច ជាត្បូងនាគា

ខ្សែមាសខ្សែបេរ បវរសោភា លួសមាសចាក់ផ្កា
កញ្ជើលស័ក្តិសម ។
ប្រដាប់គ្រែព្រះ- រាជយានល្អល្អះ សឹងមាសឧត្តម
តាមរបៀបមន់ សែនត្បាន់ក្បស់ក្ប សែងសូរ្យអភិរម្យ
រៀបរៀងត្រៀបត្រា ។
អស់អគ្គខុនណាង តែងតួស្អិតស្អាង ប្រដាប់គាត្នា
សឹងឡើងជាន់ជិះ រេះរៀងគ្នា ទៅទទួលមហា-
ក្សត្រថ្ងៃពីរពង្ស ។
អស់មុខមន្ត្រី សឹងជិះពាជី ប្រដាប់អស់អគ្គ
នាំគ្នាដង្ហែ បរបែរគម្រង់ ទៅទីស្តេចគង់
និត្យនៅចម្ការ ។
ដល់ស្រាប់ខុនអគ្គ ក្រួញក្រាបជួញជង្ឃ ប្រណម្យទូលថា
បពិត្រព្រះអង្គ ទ្រើសទ្រង់ចេស្តា យើងខ្ញុំគ្រប់គ្នា
ដើរទៅមៀងមើល ។
- យល់ភូមិមួយម- ង្គលគាប់គួរសង់ មន្ទីរប្រសើរ
ចូកចាំងប្រាសប្រាប ឲ្យរាបបរណ្តើរ ដល់ល្វាចយប់ស្មើរ



រំលមកនិទ្រា ។
លុះព្រឹកឡើងវិញ នាំគ្នាចរចេញ ទៅទីគ្រឹហា
យល់ប្រាសាទមាស ផ្ទះផ្កាស់នៅនា ភូមិទីងសង់ជា
មន្ទីរក្សត្រថ្ងៃ ។
មានតួកំពែង កែវកេតខ្វាត់ខ្វែង ព្រោងព្រាយប្រពៃ
អស្ចារ្យចំឡែក ពន់ពេកល្អក្រៃ យើងខ្ញុំទីទៃ
រួសរត់កំរង់ ។
ដល់យល់អក្ខរា នៅខ្លោងទ្វារថា ព្រះឥន្ទ្រាទ្រង់
ប្រើពិស្ណុការ សម្នាមកសង់ ធ្វើថ្វាយព្រះអង្គ
អម្ចាស់មានបុណ្យ ។
- យើងខ្ញុំចូលមើល ក្នុងឋានប្រសើរ ប្រាសាទទំពូគន់
ម្ចាស់អើយអម្ចាស់ ល្អណាស់ពេកពន់ មានឃ្លាំងទ្រព្យធន
ដូចឋានសួគ៌ា ។
- ឥឡូវយើងខ្ញុំ ចូលមកសូមសុំ អញ្ជើញក្សត្រា
ក្សត្រីបវរ ទៅគង់ប្រាង្គប្រា- សាទសោយរាជ្យជា
ឥសូរសិរសើ ។